City Bus
រថយន្តក្រុងដឹកអ្នកដំណើរ

# ការសាកល្បងជាសាធារណៈ នូវសេវារថយន្តក្រុង

## មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ

ចាប់ពីថ្ងៃទី ៥ កុម្ភៈ ដល់ថ្ងៃទី ៤ មីនា ២០១៤

កូន។! តើអ្វីទៅជាការសាកល្បងសេវាធ្វើដំណើរសាធារណៈ?

បាទម៉ាក់! ការសាកល្បងសេវាដឹកអ្នកដំណើរសាធារណៈតាមរថយន្តក្រុងដើម្បីចង់ដឹងថាប្រជាពលរដ្ឋដូចជាយើងនេះ អាចកែប្រែទម្លាប់ក្នុងការប្រើប្រាស់យានជំនិះផ្ទាល់ខ្លួនមកជាការប្រើប្រាស់រថយន្តក្រុងសាធារណៈនេះបានឬទេ។ បើយើងម្នាក់ៗអាចងាកមកប្រើប្រាស់សេវានេះបានច្រើននោះទីក្រុងយើងនឹងអាចកាត់បន្ថយការកកស្ទះចរាចរណ៍បានមួយចំណែកធំណាម៉ាក់...

*តោះ! សាកល្បងជិះរថយន្តក្រុងទាំងអស់គ្នា!*




រថយន្តដែលសាកល្បងនេះជារថយន្តទ្វារមួយ
រថយន្តពិតប្រាកដជារថយន្តដែលបំពាក់ឧបករណ៍តាមស្តង់ដាបច្ចេកទេសព្រមទាំងមានទ្វារ២

តើរថយន្តក្រុងសាកល្បងនេះនឹងរត់នៅទីណាខ្លះទៅកូន?

## ទីតាំងចំណតរង់ចាំលើផ្លូវព្រះមុនីវង្ស

1 ចំណតរង់ចាំរង្វង់មូលស្តាតចាស់
2 ចំណតរង់ចាំពេទ្យកាល់ម៉ែត្រ
3 ចំណតរង់ចាំក្រសួងព័ត៌មាន
4 ចំណតរង់ចាំសាលាពេទ្យ
5 ចំណតរង់ចាំស្តុប BKC
6 ចំណតរង់ចាំផ្សារធំថ្មី
7 ចំណតរង់ចាំស្តុបសណ្ឋាគារស
8 ចំណតរង់ចាំវត្តកោះ
9 ចំណតរង់ចាំស្តុបផ្លូវអាចារ្យស្វា
10 ចំណតរង់ចាំស្តុបពេទ្យចិន
11 ចំណតរង់ចាំផ្លូវមុនីវង្សកែង២៩៤
12 ចំណតរង់ចាំស្តុបមេភ្លើង
13 ចំណតរង់ចាំស្តុបបូកគោ
14 ចំណតរង់ចាំក្រសួងរៀបចំដែនដី
15 ចំណតរង់ចាំសាលាច្បាប់
16 ចំណតរង់ចាំសាលាបឹងត្របែក
17 ចំណតរង់ចាំស្ថានីយឧតុនិយម
18 ចំណតរង់ចាំស្ពានអាកាសក្បាលថ្នល់
19 ចំណតរង់ចាំផ្សារច្បារអំពៅ
20 ចំណតរង់ចាំស្ពានអាកាសក្បាលថ្នល់
21 ចំណតរង់ចាំស្ថានីយ៍ឧតុនិយម
22 ចំណតរង់ចាំសាលាបឹងត្របែក
23 ចំណតរង់ចាំសាលាច្បាប់
24 ចំណតរង់ចាំក្រសួងរៀបចំដែនដី
25 ចំណតរង់ចាំស្តុបបូកគោ
26 ចំណតរង់ចាំស្តុបមេភ្លើង
27 ចំណតរង់ចាំផ្លូវមុនីវង្សកែង២៩៤
28 ចំណតរង់ចាំស្តុបពេទ្យចិន
29 ចំណតរង់ចាំស្តុបផ្លូវអាចារ្យស្វា
30 ចំណតរង់ចាំវត្តកោះ
31 ចំណតរង់ចាំស្តុបសណ្ឋាគារស
32 ចំណតរង់ចាំផ្សារធំថ្មី
33 ចំណតរង់ចាំស្ថានីយ៍រថភ្លើង
34 ចំណតរង់ចាំសកលវិទ្យាល័យជាតិគ្រប់គ្រង
35 ចំណតរង់ចាំពេទ្យកាល់ម៉ែត្រ
36 ចំណតរង់ចាំរង្វង់មូលស្តាតចាស់

គឺនឹងរត់នៅតាមបណ្តោយមហាវិថីព្រះមុនីវង្សចាប់ពីស្ពានជ្រោយចង្វារដល់ផ្សារច្បារអំពៅ និងជារៀងរាល់ថ្ងៃណាម៉ាក់...

តើកូនដឹងថា រថយន្តក្រុងសាកល្បងនេះនឹងរត់ពេលណាខ្លះទេ?

រថយន្តក្រុងសាកល្បងនេះនឹងមកដល់ស្ថានីយនីមួយៗក្នុងរយៈពេលចន្លោះពី ១០ ទៅ ១៥នាទីប៉ុណ្ណោះ!

**ម៉ោងដំណើរការគឺ ៥:៣០ ព្រឹក ដល់ ៨:៣០ យប់**
**ដោយមានម៉ោងខ្លះរយៈពេលរង់ចាំអាចខុសគ្នាបន្តិចបន្តួច!**

| | |
|---|---|
| ម៉ោង 05:30-06:00 | ត្រូវរង់ចាំប្រហែល 15នាទី |
| ម៉ោង 06:00-09:00 | ត្រូវរង់ចាំប្រហែល 10នាទី |
| ម៉ោង 09:00-16:30 | ត្រូវរង់ចាំប្រហែល 15នាទី |
| ម៉ោង 16:30-19:30 | ត្រូវរង់ចាំប្រហែល 10នាទី |
| ម៉ោង 19:30-20:30 | ត្រូវរង់ចាំប្រហែល 15នាទី |

បើវាងាយស្រួលជាងមុនអញ្ចឹងប្រហែលជាថ្លៃហើយមើលទៅកូន...?

អត់ទេម៉ាក់! ក្នុងអំឡុងពេលសាកល្បងនេះ គេនឹងគិតថ្លៃសាកល្បងដូចខាងក្រោម:

**១៥០០ រៀល** ពីថ្ងៃទី ៥ កុម្ភៈ ដល់ថ្ងៃទី ៤ មីនា ២០១៤

ក្រោមកិច្ចសហប្រតិបត្តិការរវាង៖

JICA